NGO Forum on CAMBODIA

*Working Together for Positive Change* ធ្វើការរួមគ្នាដើម្បីភាពប្រសើរឡើង

# ការវិភាគ
# ការអនុវត្តថវិកាឆ្នាំ២០០៧ និង ច្បាប់ថវិកាឆ្នាំ២០០៨

# Analysis of the Implementation of the 2007 Budget and the 2008 Budget Law

ការអនុវត្តថវិកាមូលធនសម្រាប់ក្រសួងអាទិភាពទាំងប្រាំពីរ ឆ្នាំ ២០០៧

Implementation of Capital Budget for seven priority ministries, 2007




ខែមករា ឆ្នាំ២០០៨ / January 2008

គំរោងតាមដានថវិកា / Budget Monitoring Project

# ការវិភាគការអនុវត្តថវិកាឆ្នាំ២០០៧ និង ច្បាប់ថវិកាឆ្នាំ២០០៨[១]

## *តើផែនការចំណាយសម្រាប់លើកស្ទួយជីវភាពរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទស្ថិតនៅកន្លែងណា?*


### សេចក្តីសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាគឺជាស្ថាប័នដ៏ធំនិងស្មុគ្រស្មាញមួយ។ រៀងរាល់ឆ្នាំ រាជរដ្ឋាភិបាលកម្ពុជាបានប្រមូល និងចំណាយថវិការាប់រយលានដុល្លារ។ ការគ្រប់គ្រងរបស់រាជរដ្ឋាភិបាលលើកម្រិត និងវិភាជន៍នៃចំណាយសាធារណៈ គឺជាឧបករណ៏ដ៏សំខាន់បំផុតរបស់ខ្លួនក្នុងការសម្រេចបាននូវគោលដៅដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ ២០០៦-២០១០ : "ការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងឆាប់បំផុតគឺជាអាទិភាពចម្បងបំផុតរបស់រាជរដ្ឋាភិបាលកម្ពុជា"។ ដើម្បីផ្តល់អាទិភាពដល់ចំណាយកាត់បន្ថយភាពក្រីក្រ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់ក្រសួងចំនួនប្រាំពីរជាក្រសួងអាទិភាពៈ ១) ក្រសួងអប់រំ យុវជន និង កីឡា ២) ក្រសួងសុខាភិបាល ៣) ក្រសួងកិច្ចការនារី ៤) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ៥) ក្រសួងអភិវឌ្ឍន៍ជនបទ ៦) ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ និង ៧) ក្រសួងយុត្តិធម៌។ ការផ្តល់ជូនក្រសួងទាំងនេះថា 'អាទិភាព' នាំឱ្យមានការរំពឹងថាថវិការបស់ក្រសួងទាំងនេះនឹងទទួលបាននូវអាទិភាពលើស 'វិស័យមិនមែនអាទិភាព'។ ឧទាហរណ៍ វាគឺជាប្រការសមស្របដែលគេរំពឹងថា ថវិការបស់ក្រសួងអាទិភាពគួរតែទទួលបានអាទិភាពមុនគេក្នុងករណីថវិកាជាតិមានប្រាក់បន្ថែម។

ការវិភាគនេះវាយតម្លៃវិភាជន៍ថវិកាជាតិឆ្នាំ២០០៨ និង ការអនុវត្តថវិកាឆ្នាំកន្លងទៅ។ ការវិភាគនេះ ធ្វើសេចក្តីសន្និដ្ឋានសំខាន់ៗចំនួនពីរៈ សេចក្តីសន្និដ្ឋានទីមួយបញ្ជាក់ថា ការចំណាយមូលធនជាក់ស្តែងក្នុងឆ្នាំ២០០៧ មានភាពខុសប្លែកខ្លាំងពីចំនួនថវិកាដែលបានគ្រោងទុក ជាពិសេសសម្រាប់ក្រសួងចំនួនពីរដែលមានសារៈសំខាន់សម្រាប់លើកស្ទួយជីវភាពរស់នៅរបស់ប្រជាពលរដ្ឋក្រីក្រនៅជនបទ។ ក្នុងឆ្នាំ២០០៧ ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានចំណាយថវិកាចំនួន ២៣លានដុល្លារសហរដ្ឋអាមេរិក តិចជាងការគ្រោងទុកនៅក្នុងថវិកាមូលធនឆ្នាំ២០០៧ របស់ក្រសួងទាំងពីរ។


---

[១] អត្ថបទនេះត្រូវបានសរសេរដោយគម្រោងថវិការបស់វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា។ ព័ត៌មានបន្ថែមសូមទំនាក់ទំនងៈ លោក ង៉ោ សុថាត មន្ត្រីសម្របសម្រួលកម្មវិធីបញ្ហាអភិវឌ្ឍន៍: sothath@ngoforum.org.kh / ០២៣-៩៩៤០៦៣។

សេចក្តីសន្និដ្ឋានទីពីរបង្ហាញថា ផែនការថវិការបស់រាជរដ្ឋាភិបាលសម្រាប់ឆ្នាំ ២០០៨ មិនទាន់មានការផ្សារភ្ជាប់ឱ្យបានគ្រប់គ្រាន់នៅឡើយទៅនឹងគោលដៅរបស់រាជរដ្ឋាភិបាលក្នុងការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន (ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ៣.០៩)។ ទោះបីរាជរដ្ឋាភិបាលផ្តល់អាទិភាពសម្រាប់ការចំណាយនៅក្នុងវិស័យសុខាភិបាលនិងអប់រំក្តី ក៏ការចំណាយសម្រាប់វិស័យកសិកម្ម អភិវឌ្ឍន៍ជនបទ យុត្តិធម៌ កិច្ចការនារី និង ដែនដី នគរូបនីយកម្ម និងសំណង់ពុំទទួលបាននូវការផ្តល់អាទិភាពឱ្យបានសមស្របឡើយ។

*ដើម្បីគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ខ្លួន ស្ថាប័ននីតិបញ្ញត្តិបានអនុម័តច្បាប់ថវិកាដែលជាសេចក្តីថ្លែងការណ៍ មួយស្តីអំពីផែនការចំណូលនិងចំណាយរបស់រាជរដ្ឋាភិបាលសម្រាប់រយៈពេលមួយឆ្នាំ។ ថវិកានេះបានមកពី ចំណូលពន្ធដារ ថ្លៃឈ្នួលនិងថ្លៃផាកពិន័យ ជំនួយបរទេស និងពីប្រភពផ្សេងៗទៀត។ ថវិកានេះត្រូវប្រើប្រាស់សម្រាប់ចំណាយលើប្រតិបត្តិការរបស់រដ្ឋាភិបាលៈ ឧទាហរណ៍ បើកប្រាក់ខែជូនមន្ត្រីរដ្ឋបាលសាធារណៈនៅតាមក្រសួង សាលារៀន មន្ទីរពេទ្យ និងការិយាល័យនគរបាល និងវិនិយោគលើផ្លូវថ្នល់ ប្រព័ន្ធស្រោចស្រព និង អនាម័យ ។ល។ ជារួមបង្ហាញថា ការអនុវត្តមធ្យោបាយនៃការប្រមូល និង ចំណាយថវិកាធ្វើឱ្យប៉ះពាល់ដល់ប្រជាពលរដ្ឋគ្រប់រូបនៅប្រទេសកម្ពុជា។*

*នៅពេលធ្វើវិភាគចំណាយ គេត្រូវធ្វើការបែងចែកដាច់ដោយឡែកពីគ្នារវាងចំណាយចរន្ត និងចំណាយមូលធន។ ចំណាយចរន្តគឺជាការចំណាយលើទំនិញ និង សេវាកម្មនានាដែលត្រូវប្រើប្រាស់នៅក្នុងឆ្នាំបច្ចុប្បន្ន ហើយដែលចាំបាច់ត្រូវកើតមានជាដដែលៗដើម្បីទ្រទ្រង់ផលិតកម្មសេវាកម្ម។ ឧទាហរណ៍ការចំណាយទៅលើ ប្រាក់ឈ្នួល ប្រាក់ខែ ថ្លៃធ្វើដំណើរ ប្រាក់ឧបត្ថម្ភ និង ប្រាក់សោធននិវត្តន៍ជាដើម។ ការចំណាយតិចតួចលើប្រភេទសម្ភារៈផ្សេងៗដែលស្ថិតក្រោមកម្រិតថ្លៃកំណត់ជាក់លាក់ណាមួយនោះក៏ត្រូវបានចាត់ទុកថាជាចំណាយចរន្តផងដែរ។ ចំណាយមូលធនវាស់វែងពីតម្លៃនៃការទិញអចលនទ្រព្យពោលគឺទ្រព្យទាំងឡាយណាដែលត្រូវបានប្រើប្រាស់ជាដដែលៗនៅក្នុងដំណើរការផលិតកម្មដែលមានរយៈពេលលើសពីមួយឆ្នាំ។ ចំណាយមូលធនរួមមានការចំណាយលើការងារសាងសង់ ការស្តារឡើងវិញការងារជួសជុលអាគារធំៗ និង ការចំណាយទិញសម្ភារៈថ្មី ។*

## ការអនុវត្តច្បាប់ថវិកាឆ្នាំ ២០០៧

***ចំណាយចរន្ត*** សរុបក្នុងឆ្នាំ២០០៧ មានចំនួន ៦៩៥ លានដុល្លារសហរដ្ឋអាមេរិក។ ក្រសួងភាគច្រើនចំណាយថវិកាចរន្តច្រើនជាងការគ្រោងទុកនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៧។ មានតែអាជ្ញាធរសវនកម្មជាតិ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងកិច្ចការនារី និងក្រសួងយុត្តិធម៌ទេដែលចំណាយតិចជាងគម្រោងថវិកាបន្តិចបន្តួច។ ក្នុងទឹកប្រាក់ចាយលើសសរុបចំនួន ៥៩ លានដុល្លារសហរដ្ឋអាមេរិក ទឹកប្រាក់ភាគច្រើន (៣៩ លានដុល្លារសហរដ្ឋអាមេរិក) ត្រូវបានចាយដោយក្រសួងមិនមែនអាទិភាព រីឯទឹកប្រាក់ចំនួន ២០ លានដុល្លារទៀតត្រូវបានប្រើប្រាស់ដោយក្រសួងអាទិភាព (សូមមើលរូបទី ១ ខាងក្រោម)។

***រូបទី ១: ចំណាយថវិកាចរន្តលើសក្នុងឆ្នាំ ២០០៧ (លានដុល្លារសហរដ្ឋអាមេរិក)***




តារាង ១ ខាងក្រោមនេះផ្តល់នូវទិដ្ឋភាពរួមកាន់តែលម្អិតអំពី***ចំណាយចរន្ត*** របស់រាជរដ្ឋាភិបាលក្នុងឆ្នាំ ២០០៧ និងធ្វើចំណាត់ថ្នាក់ក្រសួងចំនួន ១០ ដែលបានចាយថវិកាចរន្តលើសច្រើននៅក្នុងឆ្នាំដោយមានបញ្ចូលផងដែរនូវ "ក្រសួងអាទិភាព" ទាំងអស់ដែលមិនរាប់បញ្ចូលនៅក្នុងក្រសួង ទាំងដប់ខាងលើ។ តួលេខបង្ហាញយ៉ាងច្បាស់ថាក្នុងចំណោម "ក្រសួងអាទិភាព" ទាំងប្រាំពីរ ក្រសួងអប់រំ (១១,២ លានដុល្លារ) និងក្រសួងសុខាភិបាល (៨,៣ លានដុល្លារ) បានទទួលកំណើនថវិកាជាច្រើនក្នុងឆ្នាំ ២០០៧ ប៉ុន្តែក្រសួងអាទិភាពទាំងប្រាំផ្សេងទៀតមិនបានទទួលផលប្រយោជន៍ពី ធនធានបន្ថែមដែលរាជរដ្ឋាភិ-បាលមាននៅក្នុងឆ្នាំ ២០០៧ ឡើយ។ ក្រសួងមិនមែនអាទិភាពចំនួនបួនដែលទទួលបានកំណើនខ្ពស់ជាងគេពីធនធានបន្ថែមដែលរាជរដ្ឋាភិបាលមានគឺ : ទីស្តីការគណៈរដ្ឋមន្ត្រី (៧,៩ លានដុល្លារ) ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល (៧,៤ លានដុល្លារ) ក្រសួងការបរទេស (៦,២ លានដុល្លារ) និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (៥,២ លានដុល្លារ)។ តារាង ១ ខាងក្រោមនេះបង្ហាញថាកំណើនដែលក្រសួង

ទាំងបួននេះទទួលបានគឺ សុទ្ធតែមានទឹកប្រាក់ ខ្ពស់ជាងថវិកាចរន្តសរុបរបស់ក្រសួងយុត្តិធម៌សម្រាប់ឆ្នាំ ២០០៧។

**តារាង ១: ការអនុវត្តថវិកាចរន្តឆ្នាំ ២០០៧ (គិតជាពាន់ដុល្លារសហរដ្ឋអាមេរិក)**

| ចំណាត់ថ្នាក់ | ក្រសួង / ស្ថាប័ន | ថវិកាឆ្នាំ ២០០៧ | ចំណាយឆ្នាំ ២០០៧ | ចំណាយលើស/ខ្វះ | |
|---|---|---|---|---|---|
| ១ | ក្រសួងអប់រំ យុវជន និង កីឡា | ១៣៣.១៧១ | ១៤៤.៣៨២ | ១១.២១១ | ៨% |
| ២ | ក្រសួងសុខាភិបាល | ៨២.១៧៧ | ៩០.៥៤៥ | ៨.៣៦៨ | ១០% |
| ៣ | ទីស្ដីការគណៈរដ្ឋមន្ត្រី | ២០.៧៣២ | ២៨.៦៦៥ | ៧.៩៣៤ | ៣៨% |
| ៤ | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | ២.៦៨៨ | ១០.០៨៦ | ៧.៣៩៨ | ២៧៥% |
| ៥ | ក្រសួងការបរទេស | ១៤.៦៥៩ | ២០.៨១៥ | ៦.១៥៦ | ៤២% |
| ៦ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ១០.៨៥០ | ១៦.១១៩ | ៥.២៦៩ | ៤៩% |
| ៧ | គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត | ៩១០ | ៤.៣១២ | ៣.៤០២ | ៣៧៤% |
| ៨ | ក្រសួងមហាផ្ទៃ - អគ្គនាយកដ្ឋានរដ្ឋបាល | ៦.៤៦៣ | ៩.០១១ | ២.៥៤៧ | ៣៩% |
| ៩ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង ស្ដារនីតិសម្បទា | ២៩.១០៣ | ៣១.៦៣៧ | ២.៥៣៤ | ៩% |
| ១០ | រដ្ឋសភា | ១៦.៣៤១ | ១៨.៤៨៨ | ២.១៤៦ | ១៣% |
| ១៣ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៩.០៨៨ | ៩.២៩៣ | ២០៥ | ២% |
| ១៧ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ១៤.៥០៦ | ១៤.៦១៩ | ១១៣ | ១% |
| ២២ | ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ | ៣.៩២៣ | ៣.៩៥៤ | ៣១ | ១% |
| ៣៣ | ក្រសួងកិច្ចការនារី | ៤.០០០ | ៣.៩៩៧ | (៣) | 0% |
| ៣៤ | ក្រសួងយុត្តិធម៌ | ៤.៩៩៤ | ៤.៩៥០ | (៤៤) | -១% |

ជាផ្នែកមួយនៃ***ចំណាយចរន្ត*** ក្នុងច្បាប់ថវិកាឆ្នាំ ២០០៧ រាជរដ្ឋាភិបាលបានគ្រោងថវិកាចំនួន ១៣៩ លានដុល្លារនៅក្នុងខ្ទង់***ចំណាយមិនទាន់វិភាជន៍***។ ក្នុងឆ្នាំ ២០០៧ រាជរដ្ឋាភិបាលកម្ពុជាបានចំណាយថវិកាតិចជាងផែនការឆ្នាំ ២០០៧ ចំនួន៦៣ លានដុល្លារ ហើយបានប្រើ មូលនិធិទាំងនេះសម្រាប់ធ្វើហិរញ្ញប្បទានលើចំណាយចរន្តដែលលើស។ សម្រាប់ព័ត៌មានលម្អិតស្ដីអំពីចំណាយនៃខ្ទង់ថវិកា "ចំណាយមិនទាន់វិភាជន៍" សូមមើលរូបទី២ ខាងក្រោមនេះ។

មានហេតុផលល្អៗមួយចំនួនចំពោះការបង្កើតឱ្យមានខ្ទង់ថវិកាសម្រាប់ចំណាយមិនទាន់វិភាជន៍ (ឬ មូលនិធិបម្រុង) នៅក្នុងថវិកាជាតិ ពីព្រោះមូលនិធិនេះអាចត្រូវការចាំបាច់សម្រាប់ការងារជួយសង្គ្រោះបញ្ហាគ្រោះធម្មជាតិ (ដូចជាការខ្វះខាតស្បៀងអាហារ ឬ គ្រោះទឹកជំនន់ជាដើម) ឬ សម្រាប់បម្រុងពេលដៃគូអភិវឌ្ឍន៍មិនផ្តល់ជំនួយរបស់ខ្លួនឱ្យបានទាន់ពេលវេលា ឬ មិនផ្តល់ជំនួយដែលបានសន្យា។ ប៉ុន្តែ បច្ចុប្បន្ននេះ ការប្រើប្រាស់ចំណាយមិនទាន់វិភាជន៍ ស្ថិតនៅក្រោមសិទ្ធិសម្រេចរបស់ស្ថាប័ននីតិប្រតិបត្តិ ដោយពុំមានល័ក្ខខ័ណ្ឌតម្រូវផ្លូវច្បាប់ដែលកំណត់ឱ្យស្ថាប័ននីតិប្រតិបត្តិត្រូវស្នើសុំការអនុញ្ញាតពីស្ថាប័ននីតិបញ្ញត្តិដើម្បីចាយមូលនិធិនេះ។

***រូបទី ២: ការប្រើថវិកាចំនួន ១៣៩ ដុល្លារ "ចំណាយមិនទាន់វិភាជន៍" ឆ្នាំ ២០០៧ (លានដុល្លារ)***




***ចំណាយមូលធន*** សរុបក្នុងឆ្នាំ២០០៧ មានចំនួន ៥៣៦ លានដុល្លារ។ ខណៈដែលតួលេខនៃការអនុវត្តថវិកាចរន្តជាទូទៅមានការចាយលើសថវិកាដែលបានគ្រោងទុកសម្រាប់ឆ្នាំ២០០៧ តួលេខនៃការអនុវត្តថវិកាមូលធនបង្ហាញនូវទិដ្ឋភាពចម្រុះមួយ ដែលក្នុងនោះមានក្រសួងខ្លះមិនមានចំណាយមូលនិធិទាល់តែសោះ (ដូចជា ក្រសួងការងារ និង បណ្តុះបណ្តាលវិជ្ជាជីវៈ) ហើយក្រសួងដទៃទៀតចំណាយលើសផែនការដល់ទៅ ១៦ដង (ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ)។ តួលេខនៃការអនុវត្តបង្ហាញឱ្យឃើញច្បាស់ផងដែរថាវិស័យអាទិភាពទាំងឡាយជាក់ស្តែង ពុំទទួលបានអាទិភាពទេ ពីព្រោះថាក្រសួងមិនមែនអាទិភាពចំនួន ៣ (១. ក្រសួងសាធារណៈការ និងដឹកជញ្ជូន ២. ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ៣. ក្រសួងមហាផ្ទៃ) បានចាយលើសដល់ទៅជាង ១០០ លានដុល្លារ រីឯក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានចាយ តិចជាងថវិកាគ្រោងទុកចំនួន ២៣ លានដុល្លារ (សូមមើលតារាង ២ ខាងក្រោម)។

ក្នុងចំណោមក្រសួងអាទិភាពទាំងប្រាំពីរ មានតែក្រសួងសុខាភិបាលមួយប៉ុណ្ណោះដែលបានចាយលើសថវិកាគ្រោងទុក ហើយក្រសួងអប់រំ យុវជន និងកីឡា បានចាយជិតអស់ថវិកាគ្រោងទុករបស់ខ្លួន។

តួលេខនៃការអនុវត្ត សម្រាប់ក្រសួងអាទិភាពទាំងប្រាំផ្សេងទៀតស្ថិតនៅក្រោមឆ្ងាយពីចំណុចដៅរបស់ក្រសួង។ ជាពិសេស ប្រការគួរដ៏គួរឱ្យបារម្ភនោះគឺចំណាយមូលធនដ៏ទាបសម្រាប់ក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ពីព្រោះក្រសួងទាំងពីរនេះដើរតួយ៉ាងសំខាន់នៅក្នុងការបង្កើនចំណាយសាធារណៈដើម្បីលើកកម្ពស់សេដ្ឋកិច្ចជនបទ បង្កើតការងារ និងកាត់បន្ថយភាពក្រីក្រ (សូមមើលរូបទី ៣)។

***រូបទី ៣: ការអនុវត្តថវិកាមូលធនសម្រាប់ក្រសួងអាទិភាពទាំងប្រាំពីរ ក្នុងឆ្នាំ ២០០៧***




ការពិនិត្យមើលកាន់តែលម្អិតលើតួលេខទាបនៃការអនុវត្តក្នុងឆ្នាំ ២០០៧ សម្រាប់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បង្ហាញថាគម្រោងចំនួន ៤៦ នៃគម្រោងសរុបចំនួន ៥៣ បានចាយតិចជាងការថវិកាគ្រោងទុកក្នុងឆ្នាំ ២០០៧ ដូចជា "កម្មវិធីអភិវឌ្ឍន៍កសិកម្ម[១]" (ការចំណាយនៅសល់ ៦.២ លានដុល្លារ) និងគម្រោង "វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិឧស្សាហកម្ម[២]" (ការចំណាយនៅសល់ ១.២ លានដុល្លារ)។ ក្នុងចំណោមគម្រោងសរុបទាំង២៣ នៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ គម្រោងចំនួន ២១ បានចាយតិចជាងថវិកាគ្រោងទុក។ គម្រោងដែលចាយថវិកានៅសល់ច្រើនជាងគេបំផុតគឺគម្រោងលេខ ១២០៥ "អភិវឌ្ឍន៍ជនបទតំបន់ពាយព្យ" (១.៥ លានដុល្លារ) និង គម្រោង លេខ ៤៣០ "ថែទាំផ្លូវថ្នល់ជនបទប្រវែង ២.២៣៧ គីឡូម៉ែត្រ" (២.០ លានដុល្លារ) ដែលមិនត្រូវបានអនុវត្ត ទាល់តែសោះ។

---

[១] គម្រោងលេខ ១១៤៧

[២] គម្រោងលេខ ៦៩៤

ដោយសារចំណាយមូលធននៅក្នុងក្រសួងអភិវឌ្ឍន៍ជនបទ និង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសារៈសំខាន់ក្រៃលែងក្នុងការលើកកម្ពស់សេដ្ឋកិច្ចជនបទ បង្កើតការងារ និង កាត់បន្ថយភាពក្រីក្រ សណ្ឋាននៃការចំណាយដែលបានបង្ហាញខាងលើនេះមិនមែនជាដំណឹងល្អទេសម្រាប់ប្រជាជនក្រីក្រនៅជនបទ ដែលពឹងអាស្រ័យលើវិស័យកសិកម្ម និង សកម្មភាពនានាដែលទាក់ទិននឹងកសិកម្ម។ រាជរដ្ឋាភិបាលគប្បីពន្យល់ពីការចំណាយមិនអស់នៅក្នុងវិស័យដ៏សំខាន់ទាំងនេះ និងដោះស្រាយមូលហេតុនានាដែលបង្កឱ្យមានបញ្ហានេះ ដោយយោងតាមអាទិភាពដែលបានផ្តល់ឱ្យក្រសួងទាំងនេះ។

**តារាង ២: ការអនុវត្តថវិកាមូលធនឆ្នាំ ២០០៧ (គិតជាពាន់ដុល្លារសហរដ្ឋអាមេរិក)**

| ចំណាត់ថ្នាក់ | ក្រសួង / ស្ថាប័ន | ថវិកាឆ្នាំ ២០០៧ | ចំណាយឆ្នាំ ២០០៧ | ចំណាយលើស/ខ្វះ | |
|---|---|---|---|---|---|
| ១ | ក្រសួងសាធារណការ និងដឹកជញ្ជូន | ១០៣.៤២១ | ១៦២.៨២៨ | ៥៩.៤០៧ | ៥៧% |
| ២ | ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ២.២៨៩ | ៣៩.៥០០ | ៣៧.២១១ | ១.៦២៦% |
| ៣ | ក្រសួងសុខាភិបាល | ៩៨.១៩៥ | ១២០.៣០៥ | ២២.១១០ | ២៣% |
| ៤ | ក្រសួងមហាផ្ទៃ | ១៤.២៦៥ | ២៥.៨៣៥ | ១១.៥៧០ | ៨១% |
| ៥ | អាជ្ញាធរកម្ពុជាស្តីពីសកម្មភាពដោះមីននិងសង្គ្រោះជនរងគ្រោះដោយគ្រាប់មីន | ៤០០ | ៩៣០ | ៥៣០ | ១៣៣% |
| ៦ | រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ៣៨ | ៣៨ | ០ | ០% |
| ៧ | ក្រសួងផែនការ | ៣១០ | ០ | -៣១០ | -១០០% |
| ៨ | ក្រសួងទំនាក់ទំនងរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច | ៥០០ | ០ | -៥០០ | -១០០% |
| ៩ | ក្រសួងធម្មការ និងសាសនា | ៨៥០ | ០ | -៨៥០ | -១០០% |
| ១០ | ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ | ១.២៤០ | ០ | -១.២៤០ | -១០០% |
| ១៣ | ក្រសួងយុត្តិធម៌ | ៣.៦៤១ | ១.៦៤១ | -២.០០០ | -៥៥% |
| ១៨ | ក្រសួងអប់រំ យុវជន និងកីឡា | ៧១.២១៨ | ៦៦.៩១០ | -៤.៣០៨ | -៦% |
| ២១ | ក្រសួងអភិវឌ្ឍន៍ជនបទ | ២០.៤១០ | ១៥.០៨២ | -៥.៣២៨ | -២៦% |
| ២៣ | ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ | ៨.៩៨០ | ១.៤៥០ | -៧.៥៣០ | -៨៤% |
| ២៤ | ក្រសួងកិច្ចការនារី | ១៤.៧០៧ | ៤.៥៣១ | -១០.១៧៦ | -៦៩% |
| ២៦ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ៣៦.១៦២ | ១៨.១៣២ | -១៨.០៣០ | -៥០% |

**សេចក្តីសន្និដ្ឋានលើការអនុវត្តថវិកាឆ្នាំ ២០០៧**

នៅក្នុងការអនុវត្តថវិកាឆ្នាំ ២០០៧ គេសង្កេតឃើញថារាជរដ្ឋាភិបាល អនុវត្តបានល្អក្នុងការគ្រប់គ្រង ***ថវិកាចរន្ត*** របស់ខ្លួន ពីព្រោះគ្រប់ក្រសួងទាំងអស់ទទួលបានមូលនិធិវិភាជន៍របស់ខ្លួន។ ប៉ុន្តែនៅពេលដែលមានថវិកាបន្ថែម មានតែវិស័យសុខាភិបាល និងអប់រំប៉ុណ្ណោះ ដែលទទួលបានអត្ថប្រយោជន៍ពីថវិកាបន្ថែមនេះ ខណៈដែលវិស័យអាទិភាពផ្សេងទៀតមិនត្រូវបានគេអើពើ ហើយមូលនិធិត្រូវបានចំណាយលើប្រាក់បៀវត្សរ៍ ចំណាយធ្វើដំណើរ សម្ភារៈការិយាល័យ។ល។ នៅក្នុងក្រសួងមិនមែនអាទិភាពដូចជា: ១) ទីស្តីការ គណៈរដ្ឋមន្ត្រី ២) ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ៣) ក្រសួងការបរទេស។

ការអនុវត្តថវិកាមូលធនឆ្នាំ ២០០៧ គឺមានភាពប្រសើរសម្រាប់ក្រសួងសុខាភិបាល សមរម្យសម្រាប់ក្រសួងអប់រំ និងមានភាពខ្វះខាតសម្រាប់ក្រសួងអាទិភាពទាំងប្រាំផ្សេងទៀត ជាពិសេសក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ដោយសារការកាត់បន្ថយភាពក្រីក្រឱ្យបានយ៉ាងឆាប់តាមដែលអាចធ្វើទៅបាន គឺជាអាទិភាពចម្បងបំផុតរបស់រាជរដ្ឋាភិបាល គេត្រូវតែសន្និដ្ឋានថា មានកង្វះខាតការផ្សារភ្ជាប់រវាងគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងថវិកាជាតិ។

ដោយផ្អែកទៅលើគោលដៅគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា និងការអនុវត្តច្បាប់ថវិកាឆ្នាំ ២០០៧ មានបញ្ហាពីរដែលត្រូវការការពន្យល់ពីរាជរដ្ឋាភិបាលៈ

១. តើមានការពន្យល់យ៉ាងដូចម្តេចចំពោះភាពខុសគ្នាដ៏ធំរវាងថវិកាជាតិ និងការអនុវត្ត?
២. ហេតុអ្វីបានជាក្រសួងអាទិភាពទាំងប្រាំពីរ មិនត្រូវបានផ្តល់អាទិភាពជាប្រព័ន្ធទាក់ទិននឹងការវិភាជថវិកា?

**<u>ច្បាប់ថវិកាឆ្នាំ ២០០៨</u>**

***នីតិវិធីនៃការអនុម័តថវិកាជាតិឆ្នាំ២០០៨*** គឺយោងតាមកាលវិភាគ ដែលមានចែងនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៧។ ច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងក្នុងឆ្នាំ ២០០៨ ត្រូវបានអនុម័តដោយរដ្ឋសភានៅ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ២០០៧ នៅក្នុងសម័យប្រជុំលើកទី៧ នៃនីតិកាលទីបី និងត្រូវបានឯកភាពជាឯកច្ឆ័ន្ទ ដោយព្រឹទ្ធសភាលើទម្រង់ និងទស្សនាទានច្បាប់របស់វា។ គេចាំបាច់

ត្រូវកត់សម្គាល់ថា ការបារម្ភរបស់សង្គមស៊ីវិលពាក់ព័ន្ធនឹងសេចក្តីព្រាងច្បាប់ថវិកាឆ្នាំ ២០០៨ ត្រូវបានបង្ហាញជូនតំណាងទាំងឡាយមកពីរដ្ឋសភា និងព្រឹទ្ធសភា នៅក្នុងសិក្ខាសាលាមួយដែលរៀបចំដោយវេទិកាអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា វិទ្យាស្ថានសេដ្ឋកិច្ចកម្ពុជា និងគម្រោងទ្រទ្រង់ស្ថាប័ននីតិបញ្ញត្តិកម្ពុជា-កាណាដា នៅថ្ងៃទី ២៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧។ ថ្វីបើមានការពិភាក្សាច្រើនលើសេចក្តីព្រាងច្បាប់នេះ រវាងស្ថាប័ននីតិបញ្ញត្តិ និងស្ថាប័ននីតិប្រតិបត្តិក្តី ក៏ប្រការនេះមិនបាននាំឱ្យមានការកែប្រែអ្វីទេនៅក្នុងវិភាជន៍ដោយច្បាប់ថវិកា ដែលត្រូវបានប្រកាសឱ្យប្រើប្រាស់ដោយ ព្រះមហាក្សត្រ ។

***វិភាជន៍ចំណាយចរន្ត*** សរុបនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ បានកើនឡើង ២១ ភាគរយដល់ចំនួន ៨៣៩ លានដុល្លារសហរដ្ឋអាមេរិក បើធៀបទៅនឹងច្បាប់ថវិកាឆ្នាំ ២០០៧។ ការបង្កើនដ៏ខ្ពស់បំផុតនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ គឺការបង្កើនទឹកប្រាក់ចំនួន ៤៧ លានដុល្លារសហរដ្ឋអាមេរិកសម្រាប់ចំណាយត្រៀមបំរុង (ដែលស្ថិតនៅក្នុងចំណាយមិនទាន់វិភាជន៍) ដែលធ្វើឱ្យទឹកប្រាក់សរុបរបស់វាឡើងដល់ ១៣២ លានដុល្លារសហរដ្ឋអាមេរិក សម្រាប់ថវិកាឆ្នាំ ២០០៨។ ដោយសាររាជរដ្ឋាភិបាលកម្ពុជាមិនបានចំណាយអ្វីក្រោមខ្ទង់ "ចំណាយត្រៀមបំរុង" នៅឆ្នាំ ២០០៧ (ប៉ុន្តែបានប្រើប្រាស់ចំណាយត្រៀមបំរុង ដើម្បីធ្វើហិរញ្ញប្បទានដល់ចំណាយចរន្តរបស់ក្រសួងនានា) ការបង្កើនដ៏ច្រើននៅឆ្នាំ ២០០៨នេះ សមតែមានការពន្យល់មួយ។ តាមទស្សនៈរបស់សង្គមស៊ីវិល មូលនិធិទាំងនេះគប្បីត្រូវបានបែងចែក ឱ្យដល់គម្រោងកាត់បន្ថយភាពក្រីក្រនៅតំបន់ជនបទ និងពង្រឹងស្ថាប័នតុលាការ ។ ការពន្យល់ដ៏ល្អមួយ អំពីលទ្ធភាពនៃការប្រើប្រាស់មូលនិធិទាំងនេះ គឺមានសារៈសំខាន់ណាស់ ដោយសារចំណាយនៅក្នុងប្រភេទនេះ គឺអាស្រ័យទាំងស្រុង លើឆន្ទានុសិទ្ធិរបស់ស្ថាប័ននីតិប្រតិបត្តិ ពីព្រោះថាវាមិនតម្រូវអោយមានការអនុញ្ញាតពីស្ថាប័ននីតិបញ្ញត្តិមុនការចំណាយថវិកានេះឡើយ ។

រូបទី ៤ បង្ហាញនូវទស្សនៈរួមមួយអំពីក្រសួង/ស្ថាប័នចំនួន ១០ ដែលទទួលបាននូវការបង្កើន ***ថវិកាចរន្ត*** ច្រើនបំផុត (កំណើនគិតជាភាគរយ) សម្រាប់ច្បាប់ថវិកាឆ្នាំ ២០០៨ ក៏ដូចជាក្រសួងអាទិភាពដែលមិនត្រូវបានរាប់បញ្ចូលនៅក្នុងក្រសួងកំពូលទាំងដប់នេះផងដែរ។ ចំនុចគួរអោយកត់សំគាល់មួយក្នុងរូបទី៤គឺ គ្មានក្រសួងណាមួយក្នុងចំណោម "ក្រសួងអាទិភាព" ស្ថិតនៅក្នុងចំណោមក្រសួងកំពូលទាំងដប់នេះទេ។ លេខរៀងនៅខាងមុខក្រសួងគឺជា ចំណាត់ថ្នាក់ដែលចង្អុលបង្ហាញពីទីតាំងរបស់ខ្លួនប្រៀបធៀបទៅនឹងក្រសួងផ្សេងទៀត។ ក្រសួងអភិវឌ្ឍន៍ជនបទបានទទួលការបង្កើនខ្ពស់ជាងគេបំផុតទី ១២ ហើយក្រសួងកសិកម្ម បានទទួលការបង្កើនខ្ពស់ជាងគេបំផុតទី ៣១ គិតជាភាគរយ ។

***រូបទី ៤: ការបង្កើនកំរិតខ្ពស់បំផុតនៃក្រសួងចំនួន ១០ (រាប់បញ្ចូលក្រសួងអាទិភាព) នៅក្នុងថវិកាចរន្ត សម្រាប់ឆ្នាំ ២០០៨ (%)***




តារាង ៣ ប្រៀបធៀបតួលេខសម្រាប់ផែនការចំណាយចរន្តពីច្បាប់ថវិកាឆ្នាំ ២០០៧ និង ច្បាប់ថវិកាឆ្នាំ ២០០៨ (មិនមានកែតម្រូវអតិផរណា) និង ធ្វើចំណាត់ថ្នាក់ក្រសួងកំពូលទាំងដប់ ដែលមានការបង្កើនខ្ពស់ជាងគេបំផុតគិតជាប្រាក់ដុល្លារ រួមជាមួយ "ក្រសួងអាទិភាព" ដែលមិនស្ថិតនៅក្នុងចំណោមក្រសួងកំពូលទាំងដប់។ ការបង្កើនខ្ពស់បំផុត ដែលមានបង្ហាញនៅក្នុងតារាង ៣ គឺមិនមែនសម្រាប់ក្រសួងជាក់លាក់ណាមួយទេ ប៉ុន្តែគឺជាការបង្កើនក្នុងទឹកប្រាក់ ៤៧ លានដុល្លារអាមេរិក សម្រាប់ចំណាយត្រៀមបំរុង (ដែលជាខ្ទង់រងមួយក្រោមខ្ទង់ "ចំណាយមិនទាន់វិភាជន៍) ដែលធ្វើឱ្យទឹកប្រាក់សរុបឡើងដល់ ១៣២ លានដុល្លារសហរដ្ឋអាមេរិក។

**តារាង ៣: វិភាជន៍នៅក្នុងថវិកាចរន្តឆ្នាំ ២០០៨ (គិតជាពាន់ដុល្លារសហរដ្ឋអាមេរិក)**

| ចំណាត់ថ្នាក់ | ក្រសួង / ស្ថាប័ន | ច្បាប់ថវិកាឆ្នាំ ២០០៧ ចរន្ត | ច្បាប់ថវិកាឆ្នាំ ២០០៨ ចរន្ត | កំណើន/ថយចុះ | |
|---|---|---|---|---|---|
| ១ | ចំណាយត្រៀមបំរុង (ជំពូក ០៩) | ៨៥.៣៤៥ | ១៣២.៤៨៦ | ៤៧.១៤១ | ៥៥% |
| ២ | ក្រសួងអប់រំ យុវជន និង កីឡា | ១៣៣.១៧១ | ១៥១.៧០៧ | ១៨.៥៣៧ | ១៤% |
| ៣ | ក្រសួងសុខាភិបាល | ៨២.១៧៧ | ៩៨.៧៣៣ | ១៦.៥៥៦ | ២០% |
| ៤ | ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង | ២៩.១០៣ | ៣៦.២៣៤ | ៧.១៣០ | ២៤% |

| | | | | | |
|---|---|---|---|---|---|
| | ស្ថាននីតិសម្បទា | | | | |
| ៥ | ផ្ទៃហិរញ្ញវត្ថុ (ជំពូក ៦៦) | ១២.១៩៥ | ១៨.២៩៣ | ៦.០៩៨ | ៥០% |
| ៦ | ទីស្តីការគណៈរដ្ឋមន្ត្រី | ២០.៧៣២ | ២៦.៨០៥ | ៦.០៧៣ | ២៩% |
| ៧ | ក្រសួងមហាផ្ទៃ - សន្តិសុខសាធារណៈ | ៤៥.៥៦៨ | ៥១.៣៩៨ | ៥.៨៣០ | ១៣% |
| ៨ | រដ្ឋសភា | ១៦.៣៤១ | ២០.៩៦៩ | ៤.៦២៧ | ២៨% |
| ៩ | ក្រសួងការពារជាតិ | ៧៨.១៧១ | ៨១.៧០៧ | ៣.៥៣៦ | ៥% |
| ១០ | ក្រសួងអភិវឌ្ឍន៍ជនបទ | ៩.០៨៨ | ១១.៧០២ | ២.៦១៤ | ២៩% |
| ១៥ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ១៤.៥០៦ | ១៦.១៦៣ | ១.៦៥៧ | ១១% |
| ១៩ | ក្រសួងកិច្ចការនារី | ៤.០០០ | ៥.០៨៩ | ១.០៨៩ | ២៧% |
| ២៤ | ក្រសួងយុត្តិធម៌ | ៤.៥៩៤ | ៥.៥២៧ | ៩៣២ | ២០% |
| ៣១ | ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ | ៣.៩២៣ | ៤.៧២០ | ៧៩៧ | ២០% |

***វិភាជន៍សរុបសម្រាប់ចំណាយមូលធន*** នៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ បានកើនឡើង ១០ ភាគរយ ដល់ ៦០៣ លានដុល្លារសហរដ្ឋអាមេរិក ប្រៀបធៀបទៅនឹងទឹកប្រាក់ចំនួន ៥៤៨ លានដុល្លារអាមេរិក ដែលត្រូវបានធ្វើវិភាជន៍នៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៧។ រូបទី៥ បង្ហាញនូវទិដ្ឋភាពទូទៅនៃក្រសួងឬស្ថាប័នចំនួនដប់ ដែលទទួលបាននូវការបង្កើនថវិកាមូលធនខ្ពស់បំផុត (គិតជាភាគរយ) ក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ និងក្រសួងអាទិភាពដែលពុំត្រូវបានរាប់បញ្ចូលក្នុងចំណោមក្រសួងកំពូលទាំងដប់។ រូបភាពនោះ ក៏បានបង្ហាញយ៉ាងច្បាស់ថា មានតែក្រសួងអាទិភាពពីរប៉ុណ្ណោះ (ក្រសួងកសិកម្ម និងក្រសួងសុខាភិបាល) ដែលលេចឡើងក្នុងចំណោមក្រសួងកំពូលទាំងដប់ និងក្រសួងអាទិភាពបួនទៀតដែលថវិកាមូលធនទទួលបានត្រូវបានកាត់បន្ថយ។ ដោយសារភាពចាំបាច់ក្នុងការបង្កើនចំណាយសាធារណៈនៅតាមតំបន់ជនបទ ការបង្កើន ៤២ភាគរយ របស់ថវិកាមូលធនសម្រាប់ក្រសួងកសិកម្ម គឺមានលក្ខណៈគួឱ្យសង្ឃឹម ប៉ុន្តែគេចាំបាច់ត្រូវកត់សម្គាល់ថា ចំណែកនៃការអនុវត្តក្នុងឆ្នាំ ២០០៧ មានកម្រិតត្រឹមតែ ៥០ ភាគរយប៉ុណ្ណោះ។ ការកាត់បន្ថយ ១៤ ភាគរយនៅក្នុងថវិកាមូលធនសម្រាប់ក្រសួង អភិវឌ្ឍន៍ជនបទសមតែមានការពន្យល់ពីរាជរដ្ឋាភិបាល ដោយសារវាមិនស្របគ្នាជាមួយនឹងគោលបំណងកាត់បន្ថយភាពក្រីក្រ ដែលមានចែងនៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ឆ្នាំ ២០០៦-២០១០។

***រូបទី ៥: ការបង្កើនកំរិតខ្ពស់បំផុតនៃក្រសួងចំនួន ១០ (រាប់បញ្ចូលក្រសួងអាទិភាព) នៅក្នុងថវិកាមូលធន សម្រាប់ឆ្នាំ ២០០៨ (%)***




តារាង ៤ ប្រៀបធៀបតួលេខ***ចំណាយមូលធនដែលបានគ្រោងទុក*** ពីច្បាប់ថវិកាឆ្នាំ ២០០៧ ទៅច្បាប់ថវិកាឆ្នាំ ២០០៨ គិតជាប្រាក់ដុល្លារ (មិនមានកែតម្រូវអតិផរណា) និង ធ្វើចំណាត់ថ្នាក់ក្រសួងកំពូលទាំងដប់ ដែលមានការបង្កើនថវិកាខ្ពស់ជាងគេបំផុតគិតជាប្រាក់ដុល្លារ រួមជាមួយ "ក្រសួងអាទិភាព" ដែលមិនស្ថិតនៅក្នុងចំណោមក្រសួងកំពូលទាំងដប់ ។

**តារាង ៤: វិភាជន៍ថវិកាមូលធនឆ្នាំ ២០០៨ (គិតជាពាន់ដុល្លារសហរដ្ឋអាមេរិក)**

| ចំណាត់ថ្នាក់ | ក្រសួង / ស្ថាប័ន | ច្បាប់ថវិកាឆ្នាំ ២០០៧ មូលធន | ច្បាប់ថវិកាឆ្នាំ ២០០៨ មូលធន | កំនើន/ថយចុះ | |
|---|---|---|---|---|---|
| ១ | ក្រសួងសាធារណៈការនិងដឹកជញ្ជូន | ១០៣.៤២១ | ១៣៧.០៨៧ | ៣៣.៦៦៦ | ៣៣% |
| ២ | ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ២.២៨៩ | ៣១.៥១៤ | ២៩.២២៥ | ១២៧៧% |
| ៣ | ក្រសួងសុខាភិបាល | ៩៨.១៩៥ | ១១៩.៨២៥ | ២១.៦៣០ | ២២% |
| ៤ | ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ៣៦.១៦២ | ៥១.៥១៨ | ១៥.៣៥៦ | ៤២% |
| ៥ | ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | ៤.៣៨០ | ១១.៩៩៣ | ៧.៦១៣ | ១៧៤% |

| | | | | | |
|---|---|---|---|---|---|
| ៦ | ក្រសួងអប់រំ យុវជន និង កីឡា | ៧១.២១៨ | ៧៧.៥៤១ | ៦.៣២៣ | ៩% |
| ៧ | រដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល | ២.៧៤០ | ៥.៨៧៧ | ៣.១៣៧ | ១១៤% |
| ៨ | ក្រសួងពាណិជ្ជកម្ម | ៦.២៥៩ | ៨.៤៩៧ | ២.២៣៨ | ៣៦% |
| ៩ | ក្រសួងមហាផ្ទៃ | ១៤.២៦៥ | ១៦.១២៣ | ១.៨៥៨ | ១៣% |
| ១០ | អាជ្ញាធរកម្ពុជាស្តីពីសកម្មភាពដោះមីននិងសង្គ្រោះជនរងគ្រោះដោយគ្រាប់មីន | ៤០០ | ៨៩៨ | ៤៩៨ | ១២៥% |
| ១៩ | ក្រសួងដែនដី នគរូបនីយកម្ម និង សំណង់ | ៨.៩៨០ | ៧.៦៩០ | -១.២៩០ | -១៤% |
| ២០ | ក្រសួងយុត្តិធម៌ | ៣.៦៤១ | ១.០០០ | -២.៦៤១ | -៧៣% |
| ២១ | ក្រសួងអភិវឌ្ឍន៍ជនបទ | ២០.៤១០ | ១៧.៥៨២ | -២.៨២៨ | -១៤% |
| ២៣ | ក្រសួងកិច្ចការនារី | ១៤.៧០៧ | ១០.០៦២ | -៤.៦៤៥ | -៣២% |

## សេចក្តីសន្និដ្ឋានស្តីពីថវិកាជាតិឆ្នាំ ២០០៨

ក្រសួងអាទិភាពទាំងប្រាំពីរ ដែលត្រូវបានកំណត់ដោយរាជរដ្ឋាភិបាលថា ជាក្រសួងគន្លឹះដើម្បីសម្រេចបាននូវគោលដៅកាត់បន្ថយភាពក្រីក្រ មិនទទួលបានមូលធនបន្ថែមជាប្រព័ន្ធឡើយ នៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨។ ថ្វីបើផែនការសម្រាប់ចំណាយចរន្តនៅក្នុងច្បាប់ថវិកាឆ្នាំ ២០០៨ មានគោលបំណងយ៉ាងទូលាយ សំដៅធ្វើការកែលម្អចំណាយនៅក្នុងក្រសួងអាទិភាពទាំងប្រាំពីរក្តី នេះមិនមែនជាបញ្ហាដែលកើតឡើងនៅក្នុងថវិកាមូលធនឡើយ ដោយសារវាដាក់បញ្ចូលការបង្កើនសម្រាប់តែ ១) ក្រសួងសុខាភិបាល ២) ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និង ៣) ក្រសួងអប់រំ យុវជន និងកីឡា តែប៉ុណ្ណោះ ចំណែកឯក្រសួងអាទិភាពបួនផ្សេងទៀតត្រូវបានកាត់បន្ថយថវិកា (១. ក្រសួងអភិវឌ្ឍន៍ជនបទ ២. ក្រសួងដែនដី នគរូបនីយកម្ម និងសំណង់ ៣. ក្រសួងយុត្តិធម៌ និង ៤. ក្រសួងកិច្ចការនារី)។

ដោយសារប្រជាជនក្រីក្រភាគច្រើនពឹងផ្អែកលើវិស័យកសិកម្ម និង សកម្មភាពនានាទាក់ទិននឹងកសិកម្ម គេឃើញមានភាពចាំបាច់ខ្លាំង ក្នុងការបង្កើនចំណាយសាធារណៈនៅតាមតំបន់ជនបទដើម្បីជម្រុញសេដ្ឋកិច្ចជនបទ។ ក្នុងន័យនេះ ការបង្កើន ៤២ភាគរយ នៅក្នុងថវិកាមូលធនសម្រាប់ក្រសួងកសិកម្ម គឺមានលក្ខណៈគួរឱ្យសង្ឃឹម។ ប៉ុន្តែការកាត់បន្ថយ ១៤ ភាគរយ នៅក្នុងថវិកាមូលធនសម្រាប់ក្រសួងអភិវឌ្ឍន៍ ជនបទសមតែមានការពន្យល់ពីរាជរដ្ឋាភិបាល។

ក្រៅអំពីវិភាជន៍ថវិកា ដែលហាក់បីដូចជាមិនមានលក្ខណៈជាប្រព័ន្ធទៅដល់វិស័យអាទិភាព សំណួរដ៏សំខាន់មួយទាក់ទិននឹងលទ្ធភាពនៃប្រើប្រាស់ប្រាក់ចំនួន ១៣២ លានដុល្លារសហរដ្ឋអាមេរិក ដែលត្រូវបានដាក់បញ្ចូលទៅក្នុងខ្ទង់ចំណាយត្រៀមបំរុង ចាំបាច់ត្រូវមានចម្លើយ។ អង្គការសង្គមស៊ីវិលចង់ដឹងថា ហេតុអ្វីបានជា (ប្រាក់មួយចំណែក) នៃមូលនិធិទាំងនេះ ជាឧទាហរណ៍ មិនត្រូវបានប្រើប្រាស់ សម្រាប់ចំណាយលើការធ្វើឱ្យប្រសើរឡើងនូវ ប្រាក់បៀវត្សរ៍របស់គ្រូបង្រៀន គិលានុបដ្ឋាយិកា និងវេជ្ជបណ្ឌិតទាំងឡាយ ដែលធ្វើការនៅតាមតំបន់ជនបទ សម្រាប់វិនិយោគមូលធនលើការអភិវឌ្ឍន ជនបទ កែលម្អសេវាផ្សព្វផ្សាយកសិកម្ម ឬ បង្កើនចំណាយលើកម្មវិធីការពារសង្គមនានា។